ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# របាយការណ៍
# ស្តីពី
# លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

កាលពីថ្ងៃអង្គារ ៧កើត ដល់ថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី០៨ ដល់ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២២ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត ដឹកនាំដោយ ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ ទីប្រឹក្សាក្រសួង អង្គភាពក្រោមឱវាទទាំងថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ ព្រមទាំងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូជាតិ និងអន្តរជាតិ សរុបចំនួន ៣៥០ នាក់ ។

ក្នុងរយៈពេល ២ថ្ងៃ អង្គសន្និបាតបានពិភាក្សាអំពីទិដ្ឋភាពសំខាន់ៗមួយចំនួន ជាអាទិ៍៖ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោម ២ ឆ្នាំ និងគ្រួសារក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ការងារជំនួយសង្គម និងជនអនាថា ការងារកុមារ និងការប្រគល់មុខងារពាក់ព័ន្ធនឹងកុមារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រងបន្ត ការអនុវត្តនីតិវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់ ការផ្តល់របបគោលនយោបាយជូនជនពិការក្រីក្រនៅតាមសហគមន៍ និងការកំណត់អត្តសញ្ញាណជនមានពិការ និងការអនុវត្តគោលនយោបាយមនុស្សវ័យចាស់ ឆ្នាំ២០១៧-២០៣០ ដើម្បីពិនិត្យមើលអំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណូមពរ សម្រាប់ដាក់ចេញនូវទិសដៅអាទិភាពក្នុងការអនុវត្តបន្តនៅឆ្នាំបន្តបន្ទាប់ ក្នុងគោលបំណងពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេស ជនរងគ្រោះ និងងាយរងគ្រោះ ឱ្យស្របតាមរបៀបនៃការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ ។

ជារួម អង្គសន្និបាតបានឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តដែលសម្រេចបាននាពេលនេះ ។

ក្រោយពីបានស្តាប់បទអន្តរាគមន៍របស់ប្រធានអង្គភាពជំនាញថ្នាក់កណ្តាលចំនួន ០៥ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ចំនួន ០៩ និងការផ្តល់មតិយោបល់ពីថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់អំពីបញ្ហាប្រឈម និងសំណូមពរដោះស្រាយ ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានអង្គសន្និបាត បានបូកសរុប និងផ្តល់អនុសាសន៍ដើម្បីដាក់ចេញនូវទិសដៅអនុវត្តឱ្យមានប្រសិទ្ធភាពដូចតទៅ ៖

១- អបអរសាទរលទ្ធផលដែលសម្រេចបានសមិទ្ធផលថ្មីៗរបស់ក្រសួងក្នុងឆ្នាំ២០២១ កន្លងទៅ ។

២- ពិនិត្យឡើងវិញនូវចំណេះដឹងសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារ តាមរយៈកិច្ចប្រជុំប្រមូលធាតុចូលពីថ្នាក់ដឹកនាំ អង្គភាពជំនាញ និងគ្រប់ភាគីពាក់ព័ន្ធ ។

៣- ត្រូវធ្វើបច្ចុប្បន្នភាពឡើងវិញនូវចំនួនកុមារកំព្រា កុមារពិការ កុមារងាយរងគ្រោះ នៅតាមរាជធានី ខេត្ត ។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ /ទូរសារ: (៨៥៥) ២៣ ៧២៦ ០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

៤- សិក្សាបង្កើតឱ្យមាន អគ្គនាយកដ្ឋានគោលនយោបាយ ដើម្បីសិក្សា ស្រាវជ្រាវ ប្រមូលព័ត៌មាន និងធាតុចូលសម្រាប់ដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច ។

៥- អង្គភាពជំនាញត្រូវខិតខំកសាងលិខិតបទដ្ឋានគតិយុត្តសម្រាប់ដំណើរការមណ្ឌលនីមួយៗ ដែលបានបង្កើតហើយ ដើម្បីដំណើរការឱ្យបានពេញលេញស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ ។

៦- រាល់ការងារកសាងលិខិតបទដ្ឋានគតិយុត្តិត្រូវឆ្លងកាត់ក្រុមការងារច្បាប់របស់ក្រសួង ។

៧- អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរ ត្រូវពិនិត្យមើលលិខិតបទដ្ឋានដែលពាក់ព័ន្ធការងារក្រោមសមត្ថកិច្ចរបស់ខ្លួន ។

៨- ស្នើឱ្យអង្គភាពជំនាញ និងមន្ទីរ មានកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលកើតឡើង ។

៩- អង្គភាពជំនាញ និងមន្ទីរជំនាញ ត្រូវខិតខំប្រើប្រាស់មន្ត្រីរាជការក្រោមឱវាទឱ្យអស់លទ្ធភាពក្នុងអំឡុងពេលមិនទាន់មានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការជ្រើសរើស ។

១០- ត្រៀមរៀបចំ និងដាក់ឱ្យដំណើរការកម្មវិធីជំនួយសង្គមជាកញ្ចប់គ្រួសារ តាមរយៈការធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមបញ្ចូលគ្នា រួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនពិការ ឧបត្ថម្ភមនុស្សចាស់ និងឧបត្ថម្ភសាច់ប្រាក់ជូនសិស្សក្រីក្រ ។

១១- អនុវត្តសាកល្បងក្នុងការទទួលអនីតិជនដែលទំនាស់នឹងច្បាប់ មកស្នាក់នៅ អប់រំ កែប្រែ ស្តារនីតិសម្បទា ក្នុងបរិមាណសមស្រប និងពង្រីកបរិមាណជាបន្តបន្ទាប់ ឱ្យស្របតាមសមត្ថភាព និងលទ្ធភាពរបស់មណ្ឌល ។

១២- បង្កើនប្រសិទ្ធភាពផ្តល់សេវាសុខុមាលភាព និងលើកកម្ពស់សិទ្ធជនពិការ ដោយរៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងឱ្យបានច្បាស់លាស់ បណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតមុខរបរជូនជនពិការ និងពង្រឹងពង្រីកកម្មវិធីកំណត់អត្តសញ្ញាណជនពិការតាមបែបគំរូសង្គម និងសិទ្ធមូលដ្ឋានរបស់ជនពិការ ។

១៣- ពង្រឹងប្រព័ន្ធ និងគុណភាពសេវាកិច្ចការពារកុមារ ដោយប្រមូលផ្តុំលើការបង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យថ្នាក់ជាតិ ដើម្បីគ្រប់គ្រងទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះ ។

១៤- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការគ្រប់គ្រង និងបញ្ជូនជនដែលមានវិបល្លាសស្មារតីមកមណ្ឌលថែទាំជនវិបល្លាសស្មារតីស្របតាមបទដ្ឋាន និងនីតិវិធីដែលមានស្រាប់ ។

អង្គភាពជំនាញ និង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្សព្វផ្សាយ និងអនុវត្តតាមលទ្ធផលនៃសន្និបាតខាងលើនេះឱ្យមានប្រសិទ្ធភាព ។

ថ្ងៃ ច័ន្ទ ១២រោចខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២២

រដ្ឋមន្ត្រី

វង សូត